# មណ្ឌលសិក្សាធិការយូនីហ្វៃដ៍អូកឡិនដ៍ បង្ហាញថា

# មគ្គុទ្ទេសក៍ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់មាតាបិតាក្នុងនាមជាដៃគូ ថ្នាក់ទី2

មណ្ឌលសិក្សាធិការយូនីហ្វៃដ៍អូកឡិនដ៍ ជឿទៅលើសំណុំមួយនៃជំនឿស្នូលអំពីគ្រួសារដែលយើងបម្រើជូនជារៀងរាល់ថ្ងៃ។

**ជំនឿគោល #1** មាតាបិតាទាំងអស់មានក្តីស្រមៃសម្រាប់កូនរបស់ខ្លួន និងចង់ឲ្យពួកគេល្អ

**ជំនឿគោល #2** ភាពជាដៃគូរជាមួយគ្រួសារគឺមានសារសំខាន់ចំពោះសមិទ្ធិផលនៃការសិក្សា

**ជំនឿគោល #3** មាតាបិតាទាំងអស់អាចគាំទ្រការសិក្សារបស់កូនរបស់ពួកគេបាន

**ជំនឿគោល #4** ការទទួលខុសត្រូវក្នុងការបង្កើតភាពជាដៃគូររវាងសាលា និងផ្ទះ ផ្អែកជាចំបងលើបុគ្គលិកសាលា ជាពិសេសថ្នាក់ដឹកនាំសាលា។

ពីព្រោះយើងប្រកាន់យកនូវជំនឿគោលលើការចូលរួមរបស់គ្រួសារ យើងបានបង្កើតសម្ភារ និងធនធានដើម្បីធានាថា គ្រួសារទាំងអស់យល់អំពី**ស្តង់ដារមុខវិជ្ជាស្នូល** និងអាចគាំទ្រការសិក្សានៅក្នុងផ្ទះ។ ធនធានទាំងនេះរួមមាន កញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលទាំងអស់ *(Common Core Backpack)* ដែលទាំងនោះគឺជាសកម្មភាពដែលមាតាបិតាអាចប្រើនៅផ្ទះ ដើម្បីពង្រឹងស្តង់ដារនៃមុខវិជ្ជាគោលទាំងនោះ។

| តើអ្វីគឺស្តង់ដារមុខវិជ្ជាស្នូល? | ហេតុអ្វីត្រូវការមុខវិជ្ជាស្នូល |
|---|---|
| កាលពីមុន រដ្ឋនិមួយៗមានកម្រិតស្តង់ដារអប់រំរបស់ខ្លួន។ ចំណុចនេះបានបង្កឲ្យមានការ ភាន់ច្រលំ និងក្តីបារម្ភអំពីថាតើសិស្សរបស់យើងត្រៀមខ្លួនសម្រាប់ចូល មហាវិទ្យាល័យ និងអាជីពការងារនៅក្នុងពេលបញ្ចប់ការសិក្សាពីវិទ្យាល័យ ឬអត់។ រដ្ឋកាលីហ្វ័រញ៉ាបានអនុម័តនូវស្តង់ដារមុខវិជ្ជាស្នូលនៅក្នុងឆ្នាំ 2010។<br><br>ស្តង់ដារមុខវិជ្ជាស្នូលរបស់រដ្ឋ (CCSS) គឺជាការរំពឹងទុកនៃការសិក្សាមួយនៅក្នុងសិល្បៈ ភាសាអង់គ្លេស និងគណិតវិទ្យា ដែលបានបង្កើតឡើងដើម្បីត្រៀមសិស្សថ្នាក់ទី12 (K-12) ឲ្យចូលរៀនមហាវិទ្យាល័យ និងជោគជ័យអាជីពការងារ។ CCSS បង្ហាញឲ្យដឹងអំពីអ្វីដែល ត្រូវបានរំពឹងពីសិស្ស នៅតាមកម្រិតនិមួយៗដោយឲ្យសិស្ស មាតាបិតា គ្រូបង្រៀន និង អ្នកគ្រប់គ្រងសាលា ស្ថិតនៅក្នុងទីតាំងតែមួយដូចគ្នា ខណៈពេលកំពុងធ្វើការឆ្ពោះទៅរកគោលដៅរួមគ្នា។ | ស្តង់ដារមុខវិជ្ជាស្នូលរបស់រដ្ឋគឺមានសារសំខាន់ពីព្រោះមុខវិជ្ជាទាំងនេះនឹង ជួយកុមារទាំងអស់ មិនថាពួកគេជានរណានោះទេ សុទ្ធតែរៀនជំនាញដូចគ្នាសម្រាប់ត្រៀមចូល មហាវិទ្យាល័យ និងអាជីពការងារ។ ពួកគេបង្កើតការរំពឹងទុកច្បាស់លាស់មួយសម្រាប់ អ្វីដែលកូនរបស់អ្នកគួរដឹង និងអាចធ្វើ នៅក្នុងផ្នែកសំខាន់ផ្សេងៗ៖ អក្ខរកម្ម (**ការអាន សរសេរ និយាយ** និង**ស្តាប់**លើគ្រប់ផ្នែកនៃមុខវិជ្ជា) និង**គណិតវិទ្យា**។<br><br>ប្រសិនអ្នកដឹងការរំពឹងទុកទាំងនោះគឺជាអ្វី ក្រោយមកអ្នកអាចជួយកូនរបស់អ្នករៀបចំខ្លួន ពីព្រោះលោកអ្នកគឺជាគ្រូដំបូងរបស់កូនលោកអ្នក។<br><br>សិស្សរបស់យើងគឺជាអ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ អ្នកគ្រប់គ្រង និងអ្នករចនាប្លង់ នាពេលអនាគត។ ពួកគេគឺជាអ្នកដោះស្រាយបញ្ហា និងសហការ។ មុខវិជ្ជាស្នូលត្រៀម ធ្វើឲ្យពួកគេប្រកួតប្រជែងជាមួយ មិនមែនត្រឹមតែមិត្តភ័ក្រជនជាតិ អាមេរិកកាំងនៅក្នុងរដ្ឋផ្សេងទៀតប៉ុណ្ណោះទេ ប៉ុន្តែជាមួយសិស្សដែលមកពីបណ្តាប្រទេសនានាលើពិភពលោក។ |

## តើគ្រួសារអាចគាំទ្រជោគជ័យរបស់សាលាដោយរបៀបណា?

ភាពជាដៃគូរជាមួយគ្រួសារគឺមានសារសំខាន់សម្រាប់ជោគជ័យនៃការសិក្សា។ និយាយយ៉ាងសាមញ្ញ សាលាមិនអាចអប់រំសិស្សតែម្នាក់ឯងបានទេ។ តើគ្រួសារអាចធ្វើជាដៃគូរជាមួយ សាលាបានដោយរបៀបណា?

1. ដឹងពីអ្វីដែលកូនរបស់អ្នកគួររៀននៅថ្នាក់ទី 2
2. សួរគ្រូថាតើកូនរបស់អ្នកមានទទួលជំនាញដែលបានបង្រៀនហើយឬនៅ
3. សួរថាតើលោកអ្នកអាចគាំទ្រការសិក្សានៅផ្ទះដោយរបៀបណា។ សួររកសកម្មភាពពីកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលទាំងអស់ *(Common Core Backpack)* ដែលគឺជាសកម្មភាព ដែលមាតាបិតាប្រើនៅផ្ទះជាមួយកូន

ដើម្បីទទួលបានចំណេះដឹងពីស្តង់ដារមុខវិជ្ជាស្នូលទាំងនោះ។

4. អាន អាន អាន។ សូមឲ្យកូនរបស់លោកអ្នកអានជារៀងរាល់ថ្ងៃ និងសួរសំណួរទៅពួកគេ។ ក្រោយមកទៀត ឲ្យពួកគេទៅអានអត្ថបទដើម្បីឆ្លើយសំណួរ "តើអ្នកដឹងដោយរបៀបណា?
5. ត្រូវប្រាកដថា កូនរបស់លោកអ្នកគឺកំពុងអានសៀវភៅដែលមិនមែនជាប្រលោមលោកប្រឌិត ជាញឹកញាប់។

# ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់ថ្នាក់ទី 2

នេះគឺជាបំណិន **សិល្បៈភាសាអង់គ្លេស** សំខាន់មួយចំនួនដែលត្រូវយកមកបង្រៀននៅក្នុងថ្នាក់ទី 2។ សម្រាប់តារាងស្តង់ដារមុខវិជ្ជាស្នូលរដ្ឋកាលីហ្វ័រញ៉ា សូមចូលទៅគេហទំព័រក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា (http://www.cde.ca.gov/re/cc/).

មានសកម្មភាពពីកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោល សម្រាប់ស្តង់ដារមុខវិជ្ជាស្នូលនិមួយដែលមានរៀបរាប់ក្នុងបញ្ជីខាងក្រោម:

| ស្តង់ដារមុខវិជ្ជាស្នូលរួម | | ជាទូទៅ វាមានន័យថា កូនរបស់អ្នកអាច... |
|---|---|---|
| RL.2.1 | សួរ និងឆ្លើយសំណួរដូចជា នរណា អ្វីខ្លះ កន្លែងណា ពេលណា មូលហេតុអ្វី និងដោយរបៀបណា ដើម្បីបញ្ជាក់ពីការយល់សេចក្តីលម្អិតសំខាន់នៅក្នុងអត្ថបទមួយ។ | ប្រាប់អំពីនរណា អ្វីខ្លះ កន្លែងណា ពេលណា មូលហេតុអ្វី និងដោយរបៀបណាបន្ទាប់ពីបានអានរឿងចប់។ |
| RL.2.2 | និទានរឿង រួមទាំងល្បើក និងព្រេងបុរាណពីវប្បធម៌ចម្រុះ និងកំណត់ពី<br>សារ មេរៀន ឬតម្លៃអប់រំរបស់រឿង។ | និទានរឿងឡើងវិញ។ |
| RL.2.3 | ពណ៌នាពីវិធីដែលតួអង្គក្នុងរឿងមួយឆ្លើយតបទៅនឹងព្រឹត្តិការណ៍ និងបញ្ហាប្រឈមចម្បងៗ។ | ប្រាប់ពីវិធីដែលតួអង្គក្នុងរឿងមួយឆ្លើយតបទៅនឹងផ្នែកទាំងឡាយនៅក្នុងរឿង។ |
| RI.2.1 | សួរ និងឆ្លើយសំណួរដូចជា នរណា អ្វីខ្លះ កន្លែងណា ពេលណា មូលហេតុអ្វី និងដោយរបៀបណា ដើម្បីបញ្ជាក់ពីការយល់សេចក្តីលម្អិតសំខាន់នៅក្នុងអត្ថបទមួយ។ | ប្រាប់អំពី នរណា អ្វីខ្លះ កន្លែងណា ពេលណា មូលហេតុអ្វី និងដោយរបៀបណាបន្ទាប់ពីបានអានរឿងប្រលោមលោកមិនមែនប្រឌិត។ |
| RI.2.2 | កំណត់ពីប្រធានបទសំខាន់នៃអត្ថបទដែលមានច្រើនកថាខណ្ឌ ព្រមទាំងការផ្តោតសំខាន់ទៅលើកថាខណ្ឌជាក់លាក់នៅក្នុងអត្ថបទ។ | ស្វែងរកគំនិតសំខាន់នៅក្នុងផ្នែកមួយនៃរឿងប្រលោមលោកមិនមែនប្រឌិត។ |
| RL.2.4 | ពណ៌នាអំពីពីលក្ខណៈដែលពាក្យ និងឃ្លា (ឧ. ឃ្លារណ្តំ ចំណាប់ចួន ចុងចួន និងឃ្លាសួន) មានការចួនរណ្តំ និងមានអត្ថន័យនៅក្នុងរឿង កំណាព្យ ឬចម្រៀង។ | យល់ពីលក្ខណៈដែលពាក្យប្រើប្រាស់ក្នុងរឿងអាចមានសម្លេងដូចជាតន្ត្រី។ |
| RL.2.5 | ពណ៌នាពីរចនាសម្ព័ន្ធទូទៅនៃរឿង<br>រួមទាំងវិធីនៃការចាប់ផ្តើមនៃសាច់រឿង<br>និងសេចក្តីបញ្ចប់ដែលសន្និដ្ឋានពីសកម្មភាព។ | ស្វែងរក និងយល់ពីចំណុចផ្តើម ពាក់កណ្តាល<br>និងចុងបញ្ចប់នៃសាច់រឿង។ |
| RL.2.6 | ទទួលស្គាល់ពីភាពខុសគ្នានៃទស្សនៈរបស់តួអង្គ រួមទាំងការនិយាយជាសម្លេងខុសៗគ្នាសម្រាប់តួអង្គនីមួយៗនៅពេលដែលអានការសន្ទនាឮៗ។ | ប្រាប់អំពីទស្សនៈនៃតួអង្គខុសៗគ្នា។ |
| RL.2.7 | <u>ប្រើប្រាស់ព័ត៌មានដែលទទួលបានពីរូបភាព និងពាក្យនៅក្នុងអត្ថបទ</u><br><u>បោះពុម្ព ឬឌីជីថល ដើម្បីបញ្ជាក់ការយល់អំពីតួអង្គ</u><br><u>ទស្សនីយភាព ឬឈុតឆាក។</u> | ប្រើប្រាស់ពាក្យ និងរូបភាពដើម្បីជំនួយដល់ខ្ញុំក្នុងការប្រាប់អំពីតួអង្គ ទស្សនីយភាព និងឈុតឆាក។ |
| RI.2.7 | ពន្យល់ពីលក្ខណៈនៃរូបភាពជាក់លាក់ (ឧ. ដ្យាក្រាមបង្ហាញពីលក្ខណៈដំណើរការនៃម៉ាស៊ីន) ដែលរួមចំណែក និងបញ្ជាក់បន្ថែមលើអត្ថបទ។ | ប្រើប្រាស់ដ្យាក្រាម និងរូបភាពដើម្បីជំនួយកូនរបស់អ្នកយល់ពីរឿងប្រលោមលោកមិនមែនប្រឌិត។ |
| RI.2.8 | ពណ៌នាពីវិធីដែលអ្នកនិពន្ធប្រើប្រាស់មូលហេតុដើម្បីគាំទ្រចំណុចជាក់លាក់ទាំងឡាយនៅក្នុងអត្ថបទ។ | ស្វែងរកមូលហេតុដើម្បីគាំទ្រគំនិតសំខាន់នៅក្នុងរឿងប្រលោមលោកមិនមែនប្រឌិត។ |
| RF.2.3 | ចេះ និងប្រើប្រាស់ពាក្យសព្ទតាមកម្រិតថ្នាក់ និងបំណិនវែកញែកពាក្យនៅក្នុងការបកស្រាយពាក្យ។ | អានពាក្យថ្នាក់ទីពីរ។ |

| | | |
|---|---|---|
| RF.2.4 | អានបានយ៉ាងត្រឹមត្រូវ និងស្ទាត់ជំនាញគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការយល់ដឹង។<br>a. អានអត្ថបទតាមលំដាប់ថ្នាក់ដោយមានគោលបំណង និងការយល់ដឹង។<br>b. អានអត្ថបទតាមលំដាប់ថ្នាក់ដោយផ្ទាល់មាត់ មានអត្រា<br>ត្រឹមត្រូវ និងសំនួនវោហារស័ព្ទអំពីអំណានបន្តបន្ទាប់គ្នា។<br>c. ប្រើបរិបទដើម្បីបញ្ជាក់អះអាង ឬស្វ័យកែតម្រូវការស្គាល់ការយល់ និងការអានពាក្យណាមួយឡើងវិញតាមការចាំបាច់។ | អានដោយមានការបញ្ជាក់។ អានបានយ៉ាងត្រឹមត្រូវ។ អានម្តងទៀតដើម្បីយល់<br>អត្ថន័យពាក្យ។ |

*ស្តង់ដារដែលមានភាពងាយស្រួលសម្រាប់មាតាបិតា ដែលដកស្រង់ពីលោក Jill និង Cathey Henry។ "I Can Standards." www.thecurricculumcorner.com. ថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2012*

# ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់ថ្នាក់ទី ២

ទាំងនេះគឺជាបំណិន **<u>គណិតវិទ្យា</u>** សំខាន់ៗដែលកំពុងត្រូវបានបង្រៀននៅថ្នាក់ទី 2 ។ សម្រាប់បញ្ជីទាំងស្រុងស្ដីពីស្តង់ដារមុខវិជ្ជាស្នូលរួមរបស់រដ្ឋកាលីហ្វ័រញ៉ា សូមមើល  វ៉ិបសាយរបស់ក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា (http://www.cde.ca.gov/re/cc/)។

មានសកម្មភាពកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលសម្រាប់ស្តង់ដារមុខវិជ្ជាស្នូលរួមនីមួយៗ ដូចមានរាយឈ្មោះនៅខាងក្រោម។

| ស្តង់ដារមុខវិជ្ជាស្នូលរួម | | ជាទូទៅ វាមានន័យថា កូនរបស់អ្នកអាច... |
|---|---|---|
| 2.OA.1 | ប្រើប្រាស់វិធីបូក និងវិធីដកក្នុងរង្វង់ 100 ដើម្បីដោះស្រាយចំណោទមួយជំហាន និងពីរជំហានដែលពាក់ព័ន្ធនឹងការបូក ដក ការរួមបញ្ចូល ការដកចេញ និងការប្រៀបធៀប ដោយប្រើអញ្ញាតនៅក្នុងគ្រប់ទីតាំងទាំងអស់ ឧ. ដោយប្រើគំនូរ និងសមីការដែលមាននិមិត្តសញ្ញាសម្រាប់ចំនួនដែលមិនស្គាល់ ដើម្បីតំណាងឲ្យចំណោទ។ 1 | ប្រើប្រាស់យុទ្ធសាស្ត្រដើម្បីដោះស្រាយចំណោទវិធីបូក និងវិធីដក។ |
| 2.OA.2 | បូក និងដកលេខក្នុងរង្វង់ 20 ដោយប្រើប្រាស់យុទ្ធសាស្ត្រក្នុងខួរក្បាលយ៉ាងស្ទាត់ជំនាញ។ នៅពេលបញ្ចប់ថ្នាក់ទី 2 សិស្សចាំពីការបូកចំនួនមួយតួលេខទាំងអស់ចំនួនពីរ។ | ចងចាំយ៉ាងឆាប់រហ័សនូវចម្លើយត្រឹមត្រូវនៃវិធីបូក និងវិធីដក។ |
| 2.OA.3 | កំណត់ថាតើវត្ថុមួយក្រុម (រហូតដល់ចំនួន 20) មានចំនួនសមាជិកសេស ឬចំនួនគូរដែរឬទេ ឧ. ដោយការដាក់វត្ថុជាគូរៗ ឬរាប់វត្ថុទាំងនោះម្ដង 2។ សរសេរសមីការមួយ ដើម្បីបញ្ជាក់ពីលេខគូរដែលជាផលបូកនៃចំនួនបន្ថែមពីរស្មើគ្នា។ | ដាក់វត្ថុជាក្រុមដើម្បីប្រាប់ថាជាចំនួនសេស ឬគូរ។ |
| 2.OA.4 | ប្រើប្រាស់វិធីបូកដើម្បីរកចំនួនសរុបនៃវត្ថុដែលបានរៀបនៅក្នុងលំដាប់ជួររាងចតុកោណដែលមានរហូតដល់ 5 ជួរដេក និង 5 ជួរឈរ។ សរសេរសមីការដើម្បីបញ្ជាក់ពីការសរុបផលបូកនៃចំនួនបន្ថែមស្មើគ្នា។ | ប្រើប្រាស់វិធីបូកចំនួនដដែលៗដើម្បីយល់ពីវិធីគុណ។ |
| 2.NBT.2 | រាប់ក្នុងរង្វង់ 1000។ រាប់រំលងម្ដង 5 ម្ដង 10 និងម្ដង 100។ | រាប់ក្នុងរង្វង់ 1000។ រាប់រំលងម្ដង 1 ម្ដង 5 ម្ដង 10 និងម្ដង 100។ |
| 2.NBT.4 | ប្រៀបធៀបចំនួនដែលមានបីតួលេខចំនួនពីរ ដោយផ្អែកលើអត្ថន័យនៃខ្ទង់រយ ខ្ទង់ដប់ និងខ្ទង់រាយ ដោយប្រើប្រាស់និមិត្តសញ្ញា >, =, និង < ដើម្បីកត់ត្រាលទ្ធផលនៃការប្រៀបធៀប។ | ប្រៀបធៀបចំនួនដែលមានបីតួលេខ ដោយប្រើប្រាស់និមិត្តសញ្ញា <, =, និង > ។ |
| 2.NBT.5 | បូក និងដកលេខក្នុងរង្វង់ 100 យ៉ាងស្ទាត់ជំនាញ ដោយប្រើប្រាស់យុទ្ធសាស្ត្រដែលមានមូលដ្ឋានលើតម្លៃខ្ទង់ លក្ខណ:នៃប្រមាណវិធី និង/ឬទំនាក់ទំនងរវាងវិធីបូក និងវិធីដក។ | បូក និងដកចំនួនដែលមានបីតួលេខ។ |
| 2.NBT.8 | ប្រើប្រាស់ខួរក្បាលបូកចំនួន 10 ឬ100 បន្ថែមពីលើចំនួនដែលគេផ្ដល់ឲ្យពី 100 ដល់ 900 និងប្រើខួរក្បាលដកចំនួន 10 ឬ 100 ពីចំនួនដែលគេផ្ដល់ឲ្យពី 100 ដល់ 900។ | បូក និងដកចំនួនខ្ទង់ដប់ និងខ្ទង់រយនៅក្នុងខួរក្បាល។ |
| 2.MD.7 | ប្រាប់ និងសរសេរម៉ោងពីនាឡិកាមានទ្រនិច និងនាឡិកាឌីជីថលរហូតដល់ប្រាំនាទីដែលនៅកៀកបំផុត ដោយប្រើប្រាស់ a.m. (ព្រឹក)   និង p.m (ល្ងាច)។ | ប្រាប់ម៉ោងរហូតដល់ 5 នាទី និងយល់ពី a.m. (ព្រឹក) និង p.m (ល្ងាច)។ |
| 2.MD.8 | ដោះស្រាយចំណោទពាក់ព័ន្ធនឹង ក្រដាសប្រាក់ដុល្លារ កាក់ម្ភៃប្រាំសេន កាក់ដប់សេន កាក់ប្រាំសេន កាក់មួយសេន ដោយប្រើប្រាស់និមិត្តសញ្ញា $ និង ឲ្យបានត្រឹមត្រូវ។ *ឧទាហរណ៍អ្នកមានកាក់ដប់សេនចំនួន 2 និងកាក់មួយសេនចំនួន 3 តើអ្នកមានទឹកប្រាក់សរុបប៉ុន្មានសេន?* | រាប់លុយដើម្បីជួយដល់ការដោះស្រាយចំណោទ។ |

| | | |
|---|---|---|
| 2.G.1 | ស្គាល់ និងគូររាងដែលមានលក្ខណៈជាក់លាក់ ដូចជា ប្រាប់ពីចំនួននៃមុំ ឬប្រាប់ពីចំនួនមុខស្មើៗគ្នា។ 5 កំណត់អត្តសញ្ញាណនៃ ត្រីកោណ ចតុកោណ  បញ្ចកោណ ឆកោណ និងគូប។ | ដាក់ឈ្មោះ និងគូសរាងផ្សេងៗ។ |
| 2.G.2 | បែងចែកចតុកោណទៅជាការ៉េជួរដេក និងជួរឈរដែលមានទំហំប៉ុនគ្នា និងរាប់ចំនួនដើម្បីរកចំនួនសរុបនៃការ៉េទាំងនោះ។ | រកផ្ទៃក្រលានៃចតុកោណ។ |

*ស្តង់ដារដែលមានភាពងាយស្រួលសម្រាប់មាតាបិតា ដែលដកស្រង់ពីលោក Jill និង Cathey Henry។ "I Can Standards." www.thecurricculumcorner.com. ថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2012*